# ការរំលោភបំពាន និងការរឹតត្បិតលើសេរីភាពមូលដ្ឋានដោយភាគីទី៣ នៅប្រទេសកម្ពុជា ឆ្នាំ២០២១

ភាគីទី៣ = តួអង្គមិនមែនរដ្ឋ

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន("គម្រោង") ឃ្លាំមើលលំហសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ដោយផ្តោតលើកម្រិតនៃការអនុវត្តសេរីភាពខាងសមាគម សេរីភាពខាងបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ។

**ការរំលោភបំពាន និងរឹតត្បិតលើសេរីភាពមូលដ្ឋានដោយភាគីទី៣កំពុងមានការកើនឡើង។**

នៅឆ្នាំ២០២១ គម្រោងបានកត់ត្រា៖

**៥៤** ហេតុការណ៍ដែលជាប់ទាក់ទងនឹងភាគីទី៣។

រួមមាន៖

**៤២** ការរំលោភបំពាន និង **១២** ការរឹតត្បិត[1]

ក្រុមជាក់លាក់ត្រូវបានកំណត់មុខសញ្ញា ដោយភាគីទី៣៖

**១៥** អ្នកការពារសិទ្ធិមនុស្ស

**១៤** ក្រុមសហគមន៍/តំណាងសហគមន៍

**១២** សមាជិកអតីតគណបក្សសង្គ្រោះជាតិ

**១០** សហជីព ឬ សហព័ន្ធ

ហេតុការណ៍ភាគច្រើនដែលជាប់ទាក់ទងនឹងភាគីទី៣ បានប្រព្រឹត្តិដោយជនមិនស្គាល់អត្តសញ្ញាណ។

**២១ ករណីបង្ខមកលើជនរងគ្រោះដោយជនមិនស្គាល់អត្តសញ្ញាណ**

**១១** ហេតុការណ៍បង្កឡើងដោយនិយោជក

**២០%** **នៃហេតុការណ៍ជាប់ទាក់ទងនឹងការវាយដំលើរាងកាយ** ប្រព្រឹត្តដោយជនមិនស្គាល់អត្តសញ្ញាណទៅលើជនដែលអនុវត្តសេរីភាពមូលដ្ឋាន។

**៨** ករណីជាប់ទាក់ទងនឹងបុគ្គលដែលជាប់ពាក់ព័ន្ធនឹងគណបក្សសង្គ្រោះជាតិ។

**ដំណោះស្រាយនៃការរំលោភបំពានសេរីភាពមូលដ្ឋានបង្កដោយភាគីទី៣**

**រាជរដ្ឋាភិបាលកម្ពុជា("រដ្ឋាភិបាល") មានកាតព្វកិច្ចក្នុងការគោរព និងការពារសេរីភាពមូលដ្ឋាន** ក្នុងនាមជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ក.អ.ស.ព.ន)។ ការការពារសិទ្ធិទាំងនេះ តម្រូវឱ្យរដ្ឋាភិបាលផ្តល់នូវការដោះស្រាយដល់បុគ្គលដែលរងគ្រោះដោយសារការរំលោភបំពានលើសេរីភាពមូលដ្ឋានប្រព្រឹត្តដោយភាគីទី៣។ ការដោះស្រាយអាចត្រូវបានធ្វើឡើងតាមរយៈ**ការស៊ើបអង្កេតជាបន្ទាន់ និងឯករាជ្យទៅលើការរំលោភបំពាននោះ** **ចាត់វិធានការតាមផ្លូវច្បាប់**ប្រឆាំងនឹងជនបង្កឱ្យទទួលខុសត្រូវចំពោះការរំលោភបំពាននេះ ឬ **ផ្តល់ដំណោះស្រាយសមរម្យ**ទៅជនរងគ្រោះតាមរយៈការធានាថាយុត្តិធម៌ត្រូវផ្តល់ជូន និងទទួលសំណងគ្រប់គ្រាន់ និងទាន់ពេលវេលាទៅដល់ជនរងគ្រោះ។ ការខកខានរបស់រដ្ឋាភិបាលក្នុងការផ្តល់ដំណោះស្រាយ គឺជាមិនទទួលខុសត្រូវក្នុងការគោរពនូវកាតព្វកិច្ចរបស់ខ្លួនចំពោះក.អ.ស.ព.ន។

[1] ការរឹតត្បិតអាចអនុញ្ញាតដោយស្របច្បាប់នៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន ចំណែកឯការរំលោភបំពានគឺផ្ទុយនឹងបទដ្ឋានច្បាប់អន្តរជាតិ។

ខែមេសា ឆ្នាំ២០២២

## រាជរដ្ឋាភិបាលកម្ពុជាកម្រនឹងចាត់វិធានការដោះស្រាយ

ប្រឆាំងការរំលោភបំពានសេរីភាពមូលដ្ឋានដោយភាគីទី៣




**ករណីសិក្សា: លោក ស៊ិន ខុន**

នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២១ សកម្មជនអតីតគណបក្សសង្គ្រោះជាតិ លោកស៊ិន ខុន ត្រូវបានវាយប្រហារ និងសម្លាប់ដោយក្រុមដៃដល់មិនស្គាល់អត្តសញ្ញាណនៅរាជធានីភ្នំពេញ។ ជនសង្ស័យ សៀង ធរ័ត្ន ត្រូវបានចាប់ខ្លួននៅថ្ងៃបន្ទាប់ និងបានសារភាពថា ការធ្វើឃាតនេះជាការសងសឹកទៅលើលោកស៊ិន ខុនដែលបានដេរប្រមាថប្អូនប្រុសរបស់ខ្លួន។ សង្គមស៊ីវិល និងគ្រួសាររបស់ខុន មានការសង្ស័យអំពីចម្លើយសារភាពនេះ និងយល់ថា ការស្លាប់របស់លោក ស៊ិន ខុន បណ្តាលមកពីហេតុផលនយោបាយ។ អ្នកនាំពាក្យនៃការិយាល័យអង្គការសហប្រជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានបង្ហាញនូវព្រួយបារម្ភទៅលើអសង្គតភាពនៃការបកស្រាយជាផ្លូវការនៃហេតុការណ៍នេះ និងព័ត៌មានពីការិយាល័យរបស់ពួកគេដែលទទួលបាន និងអំពាវនាវឱ្យមានការស៊ើបអង្កេតដោយឯករាជ្យ និងមិនលម្អៀងទៅលើករណីឧក្រិដ្ឋនេះ។ រដ្ឋាភិបាលមិនបានបញ្ចេញនូវព័ត៌មានបន្ថែមទៀតទេ ពាក់ព័ន្ធនឹងការចាប់ខ្លួនធរ័ត្ន ឬការចោទប្រកាន់ជនសង្ស័យណាផ្សេងទៀតនោះទេ។